ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

របាយការណ៍
ប្រជុំរួមប្រចាំខែកុម្ភៈ ឆ្នាំ២០២១
របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅព្រឹកថ្ងៃពុធ ៥រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩:០០នាទីព្រឹក នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែកុម្ភៈ ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ ជាអនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង នាយក និងនាយករងខុទ្ទកាល័យ ប្រធាននាយកដ្ឋាន នៅបន្ទប់ប្រជុំផ្ទាល់ និងឯកឧត្តម ជាទីប្រឹក្សា លោក អ្នកស្រី និងនាងកញ្ញា អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ តាមបណ្តាញវីដេអូ កម្មវិធី BlueJeans សរុបប្រមាណ៥០នាក់។

គោលបំណងនៃកិច្ចប្រជុំដើម្បី:
- បច្ចុប្បន្នភាពនៃសកម្មភាពរបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ស្ថានភាពរាលដាល និងគោលដៅនៃការឆ្លើយតបនឹងមេរោគអេដស៍ និងបទអន្តរាគមន៍។
- សមិទ្ធផលដែលសម្រេចបាន និងឧបសគ្គ ក្នុងការអនុវត្តផែនការសកម្មភាព និងផែនការបន្ត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីដំណើរការនៃកិច្ចប្រជុំ តាមរបៀបវារៈដូចខាងក្រោម ៖

១- បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន ប្រចាំខែកុម្ភៈ ឆ្នាំ២០២១ ដោយឯកឧត្តម ឈឹម ឃិនដារ៉ែត

២- បទបង្ហាញ ស្តីពីអាទិភាពនៃផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ (NSPV) និងកិច្ចសហការជាមួយដៃគូសំខាន់ៗ ដោយឯកឧត្តម វេជ្ជបណ្ឌិត **ង៉ា ផល** អនុប្រធានទទួលបន្ទុកបច្ចេកទេស។

៣- មតិសំណេះសំណាលរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី

៤- កិច្ចការផ្សេងៗ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម **ឈឹម យិនជារ៉ែត** អគ្គលេខាធិការធ្វើរបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែកុម្ភៈ ឆ្នាំ២០២១ និងលើកទិសដៅសម្រាប់ខែមីនា។

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម យិនជារ៉ែត** អគ្គលេខាធិការ បានធ្វើបទបង្ហាញដោយផ្តោតលើចំណុចសំខាន់ៗស្តីពីលទ្ធផលសកម្មភាពការងារដូចខាងក្រោម ៖

I- **បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន**

១- សកម្មភាពការងារដែលសម្រេចបាន ៖

- បានបញ្ចប់កម្មវិធីវិនិយោគសាធារណៈ (PIP)៣ឆ្នាំរំកិល សម្រាប់ឆ្នាំ២០២២-២០២៤។
- បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី២។
- បានរៀបចំកិច្ចប្រជុំប្រចាំសប្តាហ៍ និងប្រចាំខែ។
- បញ្ចប់វឌ្ឍនភាពនៃការតាមដានរួមគ្នាចំពោះសូចនាករនៃការអនុវត្តកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០១៩-២០២០ និងគោលដៅសូចនាករួម ឆ្នាំ២០២១ ដល់ឆ្នាំ២០២៣។
- បានពិភាក្សាជាមួយអភិបាលរងរាជធានី ដើម្បីរៀបចំកិច្ចប្រជុំជាន់ខ្ពស់ ស្តីពីការអនុវត្ត ស.ជ.ណ ២១៣។

២- បញ្ហាប្រឈម ៖

- ក្រុមបុរសរួមភេទជាមួយបុរសបានយល់ថា បុរសរួមភេទជាមួយបុរសមិនមានការចម្លងមេរោគអេដស៍ទេ។
- ការទំនាក់ទំនងរបស់បុរសរួមភេទជាមួយបុរសមានការងាយស្រួល ដោយគ្រាន់តែញាក់ភ្នែកដាក់គ្នា ក៏ឈានទៅដល់ការរួមភេទ។
- ស្ថានភាពជំងឺកូវីដ-១៩ នៅតែបន្តផលប៉ះពាល់ដល់ការអនុវត្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

៣- ជំហានសម្រាប់ខែបន្ទាប់ ៖

- គ្រោងរៀបចំវិបស្សនា ឆ្នាំ២០២១ (២៨-៣១មីនា នៅខេត្តក្រចេះ)។
- ជំរុញការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។
- ជំរុញការបញ្ចូលសកម្មភាព និងថវិកាឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។
- បន្តសហការជាមួយ LHSS បង្កើតM&E framework សម្រាប់អនុវត្ត NSP V & SCN 213
- បន្តជំរុញអន្តរាគមន៍កម្មវិធីការពារការចម្លងមេរោគអេដស៍ តាមរយៈអន្តរាគមន៍ផ្សព្វផ្សាយអប់រំដល់ក្រុមប្រជាជនគន្លឹះ ជាពិសេសក្រុមបុរសរួមភេទជាមួយបុរស (Condom use, PrEP, PEP, U=U)។
- បន្តវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពការងារដល់មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

II- **បទបង្ហាញ ស្តីពីអាទិភាពនៃផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (NSPV) និងកិច្ចសហការជាមួយដៃគូសំខាន់ៗ**

ឯកឧត្តមវេជ្ជ. **ផា ផណា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបង្ហាញពីសកម្មភាពជាអាទិភាពនៃពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥(NSPV) និងកិច្ចសហការជាមួយដៃគូសំខាន់ៗ ដែល ជាតួនាទីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវធ្វើដូចខាងក្រោម ៖

- បានរៀបចំកិច្ចប្រជុំ GDJ ធ្វើនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១។ កិច្ចប្រជុំនេះ ផ្តោតទៅលើការពិនិត្យ និងពិភាក្សាអំពីដំណើរការនៃរបាយការណ៍ Joint Monitoring Indicator(JMI) ពិនិត្យលើការប៉ាន់ប្រមាណការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ការធ្វើបច្ចុប្បន្នភាពនៃផែនការអាទិភាពរបស់ដៃគូនៅ ឆ្នាំ២០២១ ការពង្រឹងយន្តការសម្របសម្រួល និង AOB ផងដែរ។ កិច្ចប្រជុំលើកទី២គ្រោងនឹងរៀបចំនៅថ្ងៃទី៩ ខែមេសា ឆ្នាំ ២០២១ ដោយពិនិត្យមើលផែនការសកម្មភាពរបស់ដៃគូនីមួយៗ និងពិភាក្សាលើការពង្រឹងការសម្របសម្រួល និងតាមដានការអនុវត្តផែនការសកម្មភាពទាំងនោះអោយមានប្រសិទ្ធិភាពខ្ពស់។
- ត្រូវពង្រឹងយន្តការដឹកនាំ សម្របសម្រួល និងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។
- ត្រូវពង្រឹងយន្តការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័នដៃគូ អង្គការសង្គមស៊ីវិល និងរៀបចំឱ្យមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ស្រុក ខណ្ឌ និងឃុំ សង្កាត់គ្រប់រាជធានី ខេត្ត និងធ្វើផែនការថវិកា ដើម្បីជំរុញការងារប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យល្អប្រសើរឡើង។
- ត្រូវពង្រឹងរចនាសម្ព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនេះ ទាំងតួនាទី ទាំងថវិកា និងសូចនាករ ហើយត្រូវ ទទួលខុសត្រូវរួមគ្នា។
- ធ្វើអោយមានផែនការអនុវត្តអាទិភាព ចាត់ទុកដូចជាផែនការអាទិភាពពាក់កណ្តាលអាណត្តិ (midterm priority action) នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទី៥ដោយពិនិត្យមើលតាមយុទ្ធសាស្ត្រនីមួយៗដែលត្រូវបានសម្របសម្រួលដោយនាយកដ្ឋាននីមួយៗយោងតាមការបែងចែកភារកិច្ចក្នុងកិច្ចប្រជុំថ្នាក់អនុប្រធាន និងអគ្គលេខាធិការដ្ឋាននាពេលកន្លងទៅ។
- ត្រូវរៀបចំកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍ ដោយទាញយកជំនួយពីដៃគូអភិវឌ្ឍ ដល់ក្រុមការងារទទួលខុសត្រូវទៅលើយុទ្ធសាស្ត្រនីមួយៗដែលមាននៅក្នុងផែនការយុទ្ធសស្ត្រជាតិលើកទី៥ ដើម្បីជជែកពិភាក្សារកអាទិភាពរួមគ្នា និងរកយន្តការជំរុញការអនុវត្តអាទិភាពទាំងនោះក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍។

III)- **មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី**

បន្ទាប់មក កិច្ចប្រជុំបានដំណើរការបន្តនៅក្នុងរបៀបវារៈទី៣ ក្នុងនោះឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

១- មុខសញ្ញាសំខាន់បំផុត គឺការរួមភេទរវាងបុរសជាមួយបុរស (MSM) ដែលមានការងាយស្រួលក្នុងការទំនាក់ទំនងដើម្បីរួមភេទ គ្រាន់តែសម្លឹងមើលគ្នាដោយក្រសែភ្នែក ហើយសួរទៅដៃគូ Top ឬ Bottom ជាការស្រេច។ ជាមធ្យមពួកគាត់រកដៃគូរួមភេទបានពី៣ទៅ៤នាក់ក្នុងមួយយប់ ពេលខ្លះប្រើស្រោម ពេលខ្លះទៀតមិនប្រើស្រោមទេ។

២- ករណីក្រុមបុរសរួមភេទជាមួយបុរស ដែលមានទិន្នន័យនៃការឆ្លងថ្មីកើនឡើង អាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ ត្រូវខិតខំរកទិន្នន័យឱ្យបានច្បាស់លាស់ ហើយធ្វើបច្ចុប្បន្នភាពទិន្នន័យនោះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងជាផ្លូវការ និងយកជាការបាន។

៣- ត្រូវប្រជុំពិគ្រោះគ្នា សិក្សាពីប្រភពនៃការឆ្លង និងស្វែងរកពីវិធានការការពារ ការចម្លងមេរោគអេដស៍ និងជំងឺអេដស៍ ហើយផ្សព្វផ្សាយសារឱ្យបានទូលំទូលាយ ឱ្យទៅដល់ក្រុមគោលដៅ (MSM, TG & EW)។

៤- អគ្គលេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសជួបប្រជុំគ្នា ដើម្បីពិនិត្យមើលសកម្មភាពអាទិភាពដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រជាតិលើកទី៥ មករៀបចំជាផែនការសកម្មភាពសម្រាប់ការអនុវត្តន៍ប្រយុទ្ធនឹងជំងឺអេដស៍ បន្ទាប់មកដាក់ជូនឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពិនិត្យ និងសម្រេចជាផ្លូវការ។

៥- ក្រសួងមហាផ្ទៃមានផែនការ និងថវិកាសម្រាប់ការងារអេដស៍រួចហើយ ស្នើសុំឱ្យគាត់រៀបចំគណៈកម្មាធិការអេដស៍ថ្នាក់ខេត្ត ថ្នាក់ស្រុក ថ្នាក់ឃុំ។ ឯកឧត្តម **ខា ច៉ោ** ពិភាក្សាជាមួយប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងមហាផ្ទៃ ហើយអ.ជ.ប.ជ.អ ធ្វើសំណើទៅ **សម្តេចក្រឡាហោម** ដើម្បីចេញនូវសេចក្តីណែនាំជាផ្លូវការទៅថ្នាក់ខេត្តទូទាំងប្រទេសអនុវត្តការងារអេដស៍។

៦- ថ្នាក់ដឹកនាំទាំងអស់ត្រូវមូលមតិគ្នាផ្តល់ជាគំនិត (Conception) លើសកម្មភាពពាក់កណ្តាលអាណត្តិ (Midterm action) ហើយអ្នកបច្ចេកទេសចូលរួមស្តាប់ ដោយមានការឯកភាពរួមមួយ រួចដាក់សំណើជូន ឯកឧត្តមប្រធានពិនិត្យ និងសម្រេច។

៧- ឯកឧត្តម លោកជំទាវ ដែលទទួលបន្ទុកក្រសួង និងខេត្ត ត្រូវរៀបចំផែនការសកម្មភាពអាទិភាព ឱ្យស្របគ្នានឹងគោលការណ៍នយោបាយយុទ្ធសាស្ត្រនីមួយៗ ដើម្បីដាក់ជូនទៅក្រសួង និងខេត្តអនុវត្ត ការងារប្រយុទ្ធនឹងជំងឺអេដស៍។

៨- គម្រោងពន្លឿនទីក្រុងក្នុងការឆ្លើយតបនឹងមេរោគអេដស៍ (Fast Track City) នៅរាជធានីភ្នំពេញបានទំនាក់ទំនងរួចហើយ ប៉ុន្តែនៅខេត្តអាទិភាពដូចជា បាត់ដំបង បន្ទាយមានជ័យ និងសៀមរាប ត្រូវគិតគូធ្វើ ប្រសិនបើធ្វើមិនបានអាចរកវិធីធ្វើតាមវីដេអូខនហ្វឺរ៉ែន។

៩- អគ្គលេខាធិការដ្ឋាន រៀបចំធ្វើសិក្ខាសាលាស្តីពីការពិនិត្យឡើងវិញនូវវឌ្ឍនភាព និងសមិទ្ធិផលនៃការអនុវត្តគម្រោងផែនការសកម្មភាពនិងការរៀបចំផែនការសកម្មភាព (Retreat) មុនចូលឆ្នាំថ្មី នៅខេត្តក្រចេះ ប្រសិនបើធ្វើមិនបានអាចពិនិត្យធ្វើតាមវីដេអូខនហ្វឺរ៉ែន។

១០-ការរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលនឹងគ្រោងនៅក្នុងខែមិថុនាខាងមុខ អគ្គលេខាធិការដ្ឋាន ត្រូវរៀបចំកិច្ចប្រជុំជាពីររបៀប គឺ ១) រៀបចំកិច្ចប្រជុំនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ២)រៀបចំកិច្ចប្រជុំតាមវីដេអូខនហ្វឺរេន រៀបចំរបៀបវារៈ និងឯកសារដែលពាក់ព័ន្ធ។

១១-រាល់ឯកសារទាំងអស់ ត្រូវថតចម្លងទុកនៅក្នុងបណ្ណាល័យចំនួនមួយច្បាប់។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការងារឱ្យបានកាន់តែប្រសើរឡើង។ យើងទាំងអស់គ្នាត្រូវបន្តពិនិត្យ និងតាមដាននូវការអនុវត្តស.ជ.ណ.លេខ២១៣ ដើម្បីឆ្ពោះទៅទប់ស្កាត់ការចម្លងថ្មី។ អគ្គលេខាធិការដ្ឋាន ត្រូវបន្តរៀបចំវគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពមន្ត្រី និងអនុវត្តការងាររបស់ស្ថាប័ន ប្រព្រឹត្តទៅដោយរលូន និងរីកចម្រើន ត្រូវខិតខំប្រឹងប្រែងធ្វើការងារ កុំមើលបណ្តាំគ្នា មានសាមគ្គីភាពផ្ទៃក្នុងល្អ និងគោរពវិន័យពេលម៉ោងធ្វើការងារ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១: ១៧នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃពុធ ៥រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១
អ្នកធ្វើកំណត់ហេតុ

ស៊ឹត-ចន្ធជាន់

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

អៀង-មូលី